៥. បញ្ចូលនូវសកម្មភាពគោលនយោបាយនានា របស់ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច៥ឆ្នាំលើក ទី២ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ គោលនយោបាយជាតិប្រជាជន និងផែនការតាម វិស័យផ្សេងៗទៀត ដែលពុំទាន់សំរេចបាននៅក្នុងដំណាក់កាលផែនការ ហើយបន្ថែមនូវទិសដៅនិង វិធានការគោលនយោបាយអភិវឌ្ឍន៍ ដែលមានអាទិភាពខ្ពស់ សំរាប់ដំណាក់កាលប្រាំឆ្នាំខាងមុខ (២០០៦-២០១០)។

៦. ជាផែនការយុទ្ធសាស្ត្រជាតិមួយ ដែលតួបង្រួបបញ្ចូលគ្នានូវផែនការចក្ខុវិស័យ និងផែនការសកម្មភាពអាទិភាពរបស់រាជរដ្ឋាភិបាល ហើយដែលសមស្របទៅនឹងសក្តានុពលហិរញ្ញវត្ថុ និងសក្តានុពលផ្សេងៗទៀតរបស់សង្គមជាតិទាំងមូល ។

៧. ជាផែនការយុទ្ធសាស្ត្រជាតិមួយ ដែលនឹងត្រូវបានរៀបចំឡើង តាមរយៈការធ្វើឱ្យបានទំនាក់ទំនងល្អប្រសើរជាងមុននៃដំណើរការផែនការកម្ម និង ថវិកាកម្ម ។

៨. ជាឧបករណ៍មួយមានលក្ខណៈជាយុទ្ធសាស្ត្រ ដើម្បីសំរេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្ស កម្ពុជា ដោយបញ្ចូលគោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជាទៅក្នុងផែនការ និងកំណត់នូវគោលដៅ ទាំងឡាយ

ឱ្យមានភាពស៊ីសង្វាក់គ្នា ដើម្បីធ្វើឱ្យសំរេចបានការកាត់បន្ថយភាពក្រីក្រ និងទិសដៅ អភិវឌ្ឍន៍ ផ្នែកសង្គមកិច្ចផ្សេងៗទៀត សំដៅលើកកំពស់គុណភាពជីវភាពរស់នៅរបស់ប្រជាជន កម្ពុជាទាំងអស់ ។

៩. ជាឯកសារមួយ ដែលនឹងត្រូវបានរៀបចំឡើង នៅក្នុងដំណើរការមួយដែលរដ្ឋាភិបាលធ្វើអ្នកដឹកនាំ និងជាម្ចាស់ ហើយដោយមានការចូលរួមដ៏ទូលំទូលាយពីគ្រប់អ្នករួមចំណែកទាំងអស់ ។

II. ក្របខ័ណ្ឌស្ថាប័នសំរាប់ដំណើរការរៀបចំផែនការ

យោងតាម **ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលដើម្បីសុខដុមនីយកម្មនិងភាពរលូនស៊ីសង្វាក់គ្នា (២០០៤-២០០៨)** ដែលត្រូវបានអនុម័តនាសម័យប្រជុំគណៈរដ្ឋមន្ត្រី នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៤ ការរៀបចំកសាង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០០៦-២០១០)** ត្រូវធ្វើឡើងនៅក្នុងក្របខ័ណ្ឌ ស្ថាប័ន ដូចខាងក្រោម :

១. ក្រសួងផែនការដោយមានកិច្ចសហការជាមួយនឹងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ត្រូវបង្កើតរចនាសម្ព័ន្ធការងារសមស្របមួយ(*ក្រុមការងារបច្ចេកទេសអន្តរស្ថាប័ន*) ដែលធានានូវភាពរលូននៃការ អនុវត្តន៍ភារកិច្ចចាំបាច់សំរាប់ការរៀបចំផែនការ និងធានានូវកិច្ចសហការប្រកបដោយប្រសិទ្ធភាព ជាមួយនឹងអ្នករួមចំណែកទាំងអស់ រួមមាន ក្រសួង-ស្ថាប័នរបស់រដ្ឋាភិបាល អង្គការអន្តរជាតិ ទីភ្នាក់របស់អង្គការសហប្រជាជាតិ អង្គការក្រៅរដ្ឋាភិបាល អង្គការសង្គមស៊ីវិល ។

២. ក្រសួងផែនការត្រូវធានាការ ប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព នូវជំនួយបច្ចេកទេសដែលផ្តល់ឱ្យ ដោយអង្គការអន្តរជាតិ និងទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិមួយចំនួន ព្រមទាំងខិតខំធ្វើឱ្យមានសុខដុមនីយកម្ម នៃការរួមចំណែករបស់អ្នកផ្តល់ជំនួយនៅក្នុងដំណើរការនេះ ដើម្បីទាញយកអត្ថប្រយោជន៍ឱ្យបានច្រើនបំផុត ។

៣. ក្រសួងផែនការ ត្រូវមានភារកិច្ចរៀបចំគោលការណ៍ណែនាំបច្ចេកទេស សំរាប់ក្រសួង-ស្ថាប័ន ជំនាញពាក់ព័ន្ធ ធ្វើការវាយតំលៃពីស្ថានភាពនៃការអនុវត្តន៍សកម្មភាពគោលនយោបាយនានា របស់ ផែនការ៥ឆ្នាំលើកទី២ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ និងធ្វើការរៀបចំកសាង **យុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ (២០០៦-២០១០)** នៅក្នុងវិស័យដែលខ្លួនគ្រប់គ្រង ហើយត្រូវមាន ភារកិច្ចដឹកនាំ ការផ្តល់ការណែនាំផ្នែកបច្ចេកទេសដល់ក្រសួង-ស្ថាប័នជំនាញពាក់ព័ន្ធ ។

៤. តាមរយៈក្រុមការងារបច្ចេកទេសអន្តរស្ថាប័ន ក្រសួងផែនការនិងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ត្រូវសហការក្នុងការងារបច្ចេកទេសជាមួយ *ក្រុមការងារចំរុះតាមវិស័យរវាងរដ្ឋាភិបាលនិងអ្នកផ្តល់ ជំនួយ* ដើម្បីធានាឱ្យមានការចូលរួមដ៏ទូលំទូលាយមួយ និងដើម្បីពង្រឹងភាពជាដៃគូជាមួយអ្នករួម ចំណែក ។

៥. ក្រសួង-ស្ថាប័នជំនាញដែលពាក់ព័ន្ធទាំងអស់ត្រូវបង្កើត *ក្រុមការងារបច្ចេកទេស*មួយ ដែលដឹកនាំ ដោយរដ្ឋលេខាធិការមួយរូប ដើម្បីដឹកនាំការរៀបចំកសាង**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** នៅក្នុងវិស័យដែលខ្លួនទទួលខុសត្រូវ និងធ្វើកិច្ចសហការជាមួយនឹងក្រសួងផែនការនិងឧត្តមក្រុម ប្រឹក្សាសេដ្ឋកិច្ចជាតិ សំដៅធានានូវប្រសិទ្ធភាពនិងជោគជ័យនៅក្នុងការបំពេញភារកិច្ចរួមគ្នានេះ ។

III. កាលបរិច្ឆេទនៃការរៀបចំផែនការ

ផ្អែកតាម **ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលដើម្បីសុខដុមនីយកម្ម និងភាពរលូនស៊ីសង្វាក់គ្នា (២០០៤-២០០៨)** ការងារទាំងឡាយ ត្រូវបានគ្រោងដូចខាងក្រោម :

១. ***ធ្នូ-មករា ២០០៤:*** ក្រសួងផែនការ ដោយមានកិច្ចសហការជាមួយនឹងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ត្រូវបង្កើតជាផ្លូវការនូវយន្តការស្ថាប័នសំរាប់រៀបចំ ផែនការយុទ្ធសាស្ត្រជាតិសំរាប់អភិវឌ្ឍន៍ ដោយបង្កើត *ក្រុមការងារបច្ចេកទេសអន្តរស្ថាប័នសំរាប់ផែនការនិងការកាត់បន្ថយភាពក្រីក្រ*។

២. ***មករា-កុម្ភៈ ២០០៥:*** ក្រសួងផែនការ ត្រូវណែនាំឱ្យក្រសួង-ស្ថាប័នជំនាញពាក់ព័ន្ធ រៀបចំ ផែនការយុទ្ធសាស្ត្រតាមស្ថាប័ននីមួយៗ ដោយមានការប្រជុំបច្ចេកទេស ដែលនឹងធ្វើឡើងដើម្បី ពិភាក្សាពីដំណើរការនៃការរៀបចំ ហើយត្រូវរៀបចំគោលការណ៍ណែនាំ សំរាប់ដំណើរការនៃការ រៀបចំ ។

៣. ***កុម្ភៈ-មិថុនា ២០០៥:*** ក្រសួង-ស្ថាប័នជំនាញ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរៀងៗខ្លួន ។

៤. ***មិថុនា-សីហា ២០០៥:*** ក្រសួងផែនការត្រូវរៀបចំសេចក្តីព្រាងទីមួយនៃ**ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ** ដោយបញ្ចូលផែនការយុទ្ធសាស្ត្រតាមវិស័យ ដោយមានរៀបចំធ្វើសិក្ខាសាលា បច្ចេកទេស ។

៥. ***សីហា-កញ្ញា ២០០៥:*** ក្រសួងផែនការត្រូវរៀបចំធ្វើសិក្ខាសាលាជាតិ ដើម្បីធ្វើការពិគ្រោះ យោបល់ជាមួយអ្នករួមចំណែកទាំងអស់ ។

៦. ***កញ្ញា-តុលា ២០០៥:*** ក្រសួងផែនការ ត្រូវធ្វើការកែសំរួលសេចក្តីព្រាង**ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ** ដោយបញ្ចូលមតិយោបល់ ដែលបានលើកឡើងនៅក្នុងសិក្ខាសាលាជាតិ ។

៧. ***វិច្ឆិកា-ធ្នូ ២០០៥:*** ក្រសួងផែនការផ្ញើសេចក្តីព្រាងចុងក្រោយនៃ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ជូនគណៈរដ្ឋមន្ត្រីធ្វើការពិនិត្យសំរេច ហើយគណៈរដ្ឋមន្ត្រីផ្ញើសេចក្តីព្រាង**ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ** ទៅសុំការអនុម័តពីរដ្ឋសភានិងព្រឹទ្ធសភា ។

រាជរដ្ឋាភិបាលមានជំនឿលើស្មារតីទទួលខុសត្រូវរបស់គ្រប់ក្រសួង-ស្ថាប័ន ក្នុងការសហការជាមួយ ក្រសួងផែនការនិងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដើម្បីធ្វើការកសាង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០០៦-២០១០)** ឱ្យទទួលបានលទ្ធផលល្អប្រសើរ សមតាមខ្លឹមសារនៃសារាចរនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមករា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- អគ្គលេខាធិការដ្ឋានរដ្ឋសភា

-គ្រប់ក្រសួង ស្ថាប័ន

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី

-គ្រប់សាលាខេត្ត ក្រុង

-កាលប្បវត្តិ-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០១ សហវ.

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែមករា ឆ្នាំ២០០៥

សារាចរណែនាំ
ស្តីពី
ការកែសំរួលធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ

~~~~~~~~~~~~~

យោងតាមសារាចរលេខ០០១ សហវ.ទរចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៣ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តំរូវអោយក្រសួង-ស្ថាប័ននិងខេត្ត-ក្រុង ដែលជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌជារៀងរាល់ឆ្នាំ រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ " ។

ដើម្បីសំរួលដល់ការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ ការកាត់បន្ថយពេលវេលានិងជួយសន្សំសំចៃថវិការដ្ឋក្នុងការរៀបចំបញ្ជីសារពើភ័ណ្ឌប្រចាំឆ្នាំ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការកែសំរួលដូចតទៅ :

ការរៀបចំសៀវភៅបញ្ជីសារពើភ័ណ្ឌតាមគំរូថ្មី ដែលបានណែនាំនៅឆ្នាំ១៩៩៩កន្លងមកសំរាប់ឱ្យក្រសួង-ស្ថាប័ន និងខេត្ត-ក្រុងត្រូវធ្វើបញ្ជីសារពើភ័ណ្ឌលំអិតជារៀងរាល់ឆ្នាំរួចផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។ ប៉ុន្តែគោលបំណងនៃសារាចរណែនាំនេះ តម្រូវឱ្យធ្វើបញ្ជីសារពើភ័ណ្ឌលំអិតនេះក្នុងរយៈពេល៥ឆ្នាំម្តងវិញ ។ នៅក្នុងចន្លោះ៥ឆ្នាំនេះ ជារៀងរាល់ឆ្នាំគឺគ្រាន់តែតម្រូវឱ្យធ្វើបញ្ជីសារពើភ័ណ្ឌដោយបញ្ជាក់តែសារពើភ័ណ្ឌកើនឡើងឬថយចុះប៉ុណ្ណោះ (តាមគំរូដូចជូនភ្ជាប់) ។ដូចនេះក្រសួង-ស្ថាប័ន និងខេត្ត-ក្រុង ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌលំអិតនេះសំរាប់ឆ្នាំ២០០៤ ឱ្យបានជាដាច់ខាត ព្រោះយើងយកបញ្ជីសារពើភ័ណ្ឌឆ្នាំ ២០០៤ ជាគោលសំរាប់ប្រៀបធៀបបញ្ជីសារពើភ័ណ្ឌឆ្នាំ២០០៥ និងនៅបណ្តាឆ្នាំក្នុងចន្លោះ៥ឆ្នាំនេះស្តីពីការកើនឡើងនិងថយចុះនៃទ្រព្យសម្បត្តិរដ្ឋ ។

ការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋត្រូវដំណើរការដូចខាងក្រោមនេះ :

១-នៅក្នុងឆ្នាំនីមួយៗក្នុងចន្លោះរយៈពេល៥ឆ្នាំនេះ គ្រប់ក្រសួង-ស្ថាប័ន ខេត្ត-ក្រុង និងមន្ទីរជំនាញគ្រាន់តែធ្វើតារាងប្រៀបធៀបនៃការកើនឡើង ឬ ថយចុះទ្រព្យសម្បត្តិរដ្ឋក្នុងឆ្នាំនីមួយៗតាមចំនុចទាំង៤ នៅក្នុងតារាងប្រៀប - ធៀបនេះ (សូមជូនភ្ជាប់តារាងគំរូ) ។

២-នីតិវិធីក្នុងការរៀបចំតារាងប្រៀបធៀបនេះរួមមាន :

-សំរាប់បញ្ជីសារពើភ័ណ្ឌក្រសួង-ស្ថាប័ន :នៅលើតារាងប្រៀបធៀបត្រូវមានចុះហត្ថលេខារបស់សមា-
~~~~~~~~~~~~~

ជិកគណៈកម្មការត្រួតពិនិត្យ ប្រធានអង្គភាពប្រើប្រាស់ អ្នកទទួលខុសត្រូវកណ្តាលបញ្ជីសារពើភ័ណ្ឌ និងឯកឧត្តមប្រធានគណៈកម្មការកណ្តាលនៃបញ្ជីសារពើភ័ណ្ឌ រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុចំនួន០២ច្បាប់ ។

-សំរាប់បញ្ជីសារពើភ័ណ្ឌខេត្ត-ក្រុងៈនៅលើតារាងប្រៀបធៀបត្រូវមានចុះហត្ថលេខារបស់សមាជិកគណៈកម្មការត្រួតពិនិត្យ ប្រធានអង្គភាពប្រើប្រាស់ ប្រធានមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត-ក្រុង និងមានការឯកភាពពីឯកឧត្តមអភិបាលខេត្ត-ក្រុង ឬ អភិបាលរងខេត្ត-ក្រុង ដែលជាប្រធានគណៈកម្មការបញ្ជីសារពើភ័ណ្ឌនៅលើតារាងនេះ រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុចំនួន០២ច្បាប់ ។

៣-បញ្ជីសារពើភ័ណ្ឌចាត់ទុកជាផ្លូវការបានលុះត្រាណាមានបញ្ជីសារពើភ័ណ្ឌលំអិតឆ្នាំ២០០៤និងក្រោយមកមានបញ្ជីសារពើភ័ណ្ឌសំរាប់រយៈពេល៥ឆ្នាំម្តង១ធ្វើជាមូលដ្ឋាន ។ ក្នុងការត្រួតពិនិត្យត្រូវមានកំណត់ហេតុប្រជុំផ្លូវផ្លូងដោយមានការចូលរួមពីក្រសួងសាមីនិងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

៤-រាល់ទ្រព្យសម្បត្តិរដ្ឋ ដែលប្រើប្រាស់លែងកើតត្រូវតែរៀបចំបែបបទសុំគោលការណ៍ជំរះចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋឱ្យបានទាន់ពេលវេលា ដើម្បីជៀសវាងការបាត់បង់គ្រឿងបន្លាស់ជាបន្តបន្ទាប់ និងដើម្បីកាត់បន្ថយចំណាយថវិកាចំពោះមធ្យោបាយយានយន្តនិងគ្រឿងចក្រដែលខូចខាតនិងប្រើការពុំបាន ។

ទទួលបានសារាចរនេះគ្រប់ក្រសួង-ស្ថាប័ន និងខេត្ត-ក្រុង ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចំលងជូន
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន-ស្ថាប័ន
-គ្រប់ខេត្ត-ក្រុង
-គ្រប់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ឯកសារ

saraclier 2004

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង_ស្ថាប័ន.................

តារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង_ថយចុះ

ក្នុងឆ្នាំ.................របស់នាយកដ្ឋានឬអង្គភាព

គំរូ

ល.រ	បរិយាយ	ឯកតាគិត	ឆ្នាំ២០០៤	ឆ្នាំ២០០៥	ស្ថានភាព		ចំនួនទឹកប្រាក់
			បរិមាណ	បរិមាណ	ថយចុះ	កើនឡើង	
I-	ដីធ្លី និង អាគារ						
១	នាយកដ្ឋាន......	$ម^2$					
	អាគារ						
២	អង្គភាព.........						
	អាគារ						
II-	បរិក្ខារបច្ចេកទេសនិងឧស្សាហកម្ម						
១	ម៉ាស៊ីនភ្លើង	គ្រឿង					
២	....						
III-	រថយន្តនិងគ្រឿងចក្រ						
១	រថយន្ត						
២	ម៉ូតូ						
៣	....						
IV-	សំភារៈនិងសង្ហារឹម						
១	តុ,ទូ....						

បានឃើញនិងឯកភាព

ប្រធានគណៈកម្មការនៃបញ្ជីសារពើភ័ណ្ឌខេត្ត_ក្រុង   អ្នកទទួលខុសត្រូវកណ្តាលបញ្ជីសារពើភ័ណ្ឌ   ប្រធានអង្គភាពប្រើប្រាស់   សមាជិកគណៈកម្មការត្រួតពិនិត្យ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត-ក្រុង..................

តារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង-ថយចុះ
ក្នុងឆ្នាំ................របស់មន្ទីរ,សាលាស្រុកនិងសាលាខណ្ឌ

គំរូ

ល.រ	បរិយាយ	ឯកតាគិត	ឆ្នាំ២០០៤	ឆ្នាំ២០០៥	ស្ថានភាព		ចំនួនពិតប្រាកដ
			បរិមាណ	បរិមាណ	ថយចុះ	កើនឡើង	
I-	ដីធ្លី និង អាគារ						
១	ដីខណ្ឌ៧មករា	ម²					
	អាគារ						
២	ដីខណ្ឌដង្កោ						
	អាគារ						
II-	បរិក្ខាបច្ចេកទេសនិងឧស្សាហកម្ម						
១	ម៉ាស៊ីនភ្លើង	គ្រឿង					
២	....						
III-	វេយន្តនិងគ្រឿងចក្រ						
១	រថយន្ត						
២	ម៉ូតូ						
៣	....						
IV-	សំភារៈនិងសម្ភារិម						
១	តុ,ទូ............						

បានឃើញនិងឯកភាព

ប្រធានគណៈកម្មការនៃបញ្ជីសារពើភ័ណ្ឌខេត្ត-ក្រុង ប្រធានមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធានអង្គភាពប្រើប្រាស់ សមាជិកគណៈកម្មការត្រួតពិនិត្យ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...០០២.....សហវ.ហម

សារាចរណែនាំ

ស្តីពីការអនុវត្តន៍ថវិកាខេត្ត ក្រុង ឆ្នាំ ២០០៥

យោងតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម នស/រកម/១២០៤/០២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៤ប្រកាសលេខ ២០៣ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីបទបញ្ញាថវិការបស់ខេត្ត ក្រុង និងប្រកាសពីលេខ ០០៦ សហវ.ហម ដល់លេខ ០២៩ សហវ.ហម ចុះថ្ងៃទី១២ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការប្រគល់ភារកិច្ចប្រមូលចំណូល និងការបែងចែក ឥណទានថវិកាខេត្ត ក្រុង សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំដូចតទៅ ៖

ក. អំពីចំណូល

១. ចំណូលសារពើពន្ធ

ចំពោះមុខសញ្ញាចំណូលសារពើពន្ធ ដែលច្បាប់បានអនុញ្ញាតអោយប្រមូលសំរាប់ ជាគុណប្រយោជន៍នៃថវិកាខេត្ត ក្រុងនោះ ខេត្ត ក្រុងត្រូវជំរុញ និងតាមដានការអនុវត្តន៍គោលនយោបាយពន្ធដារអោយបានត្រឹមត្រូវរបស់មន្ត្រីពន្ធដារ និងត្រូវរួម ចំណែកដាក់ចេញវិធានការដាក់ស្តែងសំរាប់ប្រភេទពន្ធដារនីមួយៗ ដើម្បីតម្រូវអោយអ្នកជាប់ពន្ធ បង់ពន្ធបានត្រឹមត្រូវគ្រប់គ្រាន់ និងទាន់ពេលវេលា។ ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ បានអនុញ្ញាតអោយខេត្ត ក្រុងប្រមូលអាករសំរាប់ បំភ្លឺសាធារណៈចំនួន ៣% លើតំលៃស្រាបៀរ និងបារី ដែលលក់នៅក្នុងមណ្ឌលដែនដីរបស់ខ្លួន ដូច្នេះខេត្ត ក្រុងត្រូវជួយជំរុញការអនុវត្តន៍ប្រមូលអាករនេះអោយទទួលបានលទ្ធផលល្អ។

២. ចំណូលមិនមែនសារពើពន្ធ

ចំពោះចំណូលមិនមែនសារពើពន្ធ ដែលច្បាប់បានអនុញ្ញាតអោយប្រមូលសំរាប់ថវិកាខេត្ត ក្រុងនោះ ខេត្ត ក្រុងត្រូវយក ចិត្តទុកដាក់ស្រាវជ្រាវកំណត់មុខសញ្ញាចំណូលដែលត្រូវប្រមូលបង់ចូលរតនាគារអោយអស់ មិនត្រូវទុកចំណូលខ្លះ នៅដោយឡែក សំរាប់ចំណាយដោយឡែកក្រៅពីតំរោងចំណាយប្រចាំឆ្នាំឡើយ ។ ចំពោះចំណូលមិនមែនសារពើពន្ធដទៃទៀត ដែលខេត្ត ក្រុង បានប្រមូលក្រៅពីការអនុញ្ញាតដោយច្បាប់ ក៏ត្រូវបង់ចូលថវិកាខេត្ត ក្រុងដែរ ជៀសវាងទុកចំណូលនោះដោយឡែក សំរាប់ចំណាយដោយឡែក គ្មានតម្លាភាព ។ ចំពោះមុខសញ្ញាចំណូលដែលបានកំណត់រួចហើយ បើក្នុងលក្ខណ្ឌដែលត្រូវប្រមូលតាមវិធីដេញថ្លៃជាសាធារណៈនោះ ត្រូវធ្វើអោយមានតម្លាភាពពិតប្រាកដ មិនត្រូវបង្កើតការដេញថ្លៃតែរូបភាពនោះទេ ទន្ទឹមនោះត្រូវយកចិត្តទុកដាក់ជំរុញការបង់ចំណូលអោយបានត្រឹមត្រូវតាមការកំណត់ដែលមានចែងក្នុងកិច្ចសន្យា ។

៣. ចំណូលឧបត្ថម្ភពីថវិការដ្ឋ និងការរៀបចំកម្មវិធីចំណូល ចំណាយ

ចំពោះខេត្ត ក្រុង ដែលត្រូវបំពេញគុណ្យភាពដោយការឧបត្ថម្ភពីថវិការដ្ឋ ទោះបីបានកត់ត្រាតួលេខចំណូលឧបត្ថម្ភ ពីថវិការដ្ឋនៅក្នុងគំរោងថវិការបស់ខ្លួនក៏ដោយ ក៏មិនមានន័យថាថវិការដ្ឋត្រូវតែដាច់ខាតឧបត្ថម្ភតាមចំនួននោះទេ ។ ចំណូល ឧបត្ថម្ភពីថវិការដ្ឋ គឺត្រូវពិនិត្យឧបត្ថម្ភជូនខេត្ត ក្រុង ដោយផ្អែកទៅតាមស្ថានភាពជាក់ស្តែងនៃគុណ្យភាពថវិការដ្ឋ និងទៅតាមសភាពការណ៍ជាក់ស្តែងនៃការអនុវត្តន៍ចំណូល ចំណាយថវិការបស់ខេត្ត ក្រុង ។

នៅដើមត្រីមាសទី ១ ផ្អែកលើគំរោងថវិកាប្រចាំឆ្នាំ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រកាសជូនកម្មវិធីចំណូល ចំណាយរបស់ខេត្ត ក្រុងនីមួយៗ សំរាប់ត្រីមាសទី ១ ហើយនៅចុងត្រីមាសនីមួយៗ ខេត្ត ក្រុងទាំងអស់ (ទាំងខេត្ត ក្រុងបានទទួល និងមិនបានទទួលការឧបត្ថម្ភគុណ្យភាពពីថវិការដ្ឋ) ត្រូវផ្ញើកម្មវិធីចំណូល ចំណាយសំរាប់ត្រីមាសបន្ទាប់មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យសំរេចដែលភ្ជាប់មកជាមួយនូវឯកសារដែលពាក់ព័ន្ធដល់ការអនុវត្តន៍កម្មវិធីនេះ ។ យ៉ាងយូរបំផុតមួយសប្តាហ៍នៃត្រីមាសបន្ទាប់ ក្នុងករណីដែលខេត្ត ក្រុងណា ពុំបានផ្ញើកម្មវិធីចំណូល ចំណាយមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្ត ក្រុងនោះត្រូវអនុវត្តតាមកម្មវិធីចំណូល ចំណាយប្រចាំត្រីមាសដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានប្រកាសជូន ។

៣.១ ចំណូលឧបត្ថម្ភពីថវិការដ្ឋ

ចំពោះចំណូលនេះ ខេត្ត ក្រុងត្រូវធ្វើសំណើសុំឧបត្ថម្ភគុណ្យភាពប្រចាំត្រីមាសនីមួយៗ មកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមរយៈក្រសួងមហាផ្ទៃ ។ នៅដើមត្រីមាសទី ១ នេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងផ្តល់ថវិកាឧបត្ថម្ភគុណ្យភាពជូនខេត្ត ក្រុង ដោយផ្អែកលើមូលដ្ឋាន ៣/១២ នៃគំរោងឧបត្ថម្ភគុណ្យភាពប្រចាំឆ្នាំ ដោយមិនបាច់មានការស្នើសុំទេ ។ ដោយឡែកសំរាប់ត្រីមាសទី ២ ទី ៣ និងទី ៤ ខេត្ត ក្រុង ត្រូវធ្វើសំណើសុំថវិកាឧបត្ថម្ភគុណ្យភាពនៅខែចុងត្រីមាសមុនសំរាប់ត្រីមាសបន្ទាប់ ដោយភ្ជាប់មកជាមួយនូវកម្មវិធីចំណូល ចំណាយប្រចាំត្រីមាស ដែលមានលំអិតតាមខែនីមួយៗ និងចំនួនឱនភាព ដែលចាំបាច់ត្រូវសុំ ឧបត្ថម្ភគុណ្យភាព ។ កម្មវិធីចំណូល ចំណាយខាងលើនេះ ត្រូវធ្វើលំអិតទៅតាមជំពូក ប្រការ កថាខ័ណ្ឌ វាក្យខ័ណ្ឌនៃមាតិកាថវិកា និងត្រូវមានឯកសារជាផ្លូវការសំរាប់បញ្ជាក់អំពីលទ្ធភាពកេណ្ឌប្រមូលចំណូល និងតំរូវការចំណាយពិតប្រាកដដូចជា ៖

- តារាងក្របខ័ណ្ឌមន្ត្រីរាជការ បៀវត្សនិងប្រាក់បំណាច់ប្រចាំខែ និងឯកសារពាក់ព័ន្ធបុគ្គលិកអណ្តែតភ្នាក់ងារជាប់កិច្ចសន្យា (តាមតារាងគំរូភ្ជាប់ជាមួយ)
- ដីកាស្តីពីការបង្កើតរដ្ឋទេយ្យបុរេប្រទាន
- របាយការណ៍សរុបចំណូល ចំណាយជាក់ស្តែងរហូតដល់ខែចុងក្រោយ ដោយមានហត្ថលេខាបញ្ជាក់ពីរតនាគារខេត្ត ក្រុង
- តារាងចាត់ស្មានចំណូល របស់សាខាពន្ធដារខេត្ត ក្រុង និងរបស់អង្គភាពនានាដែលពាក់ព័ន្ធដល់ការប្រមូលចំណូលមិនមែនសារពើពន្ធ ដោយមានភ្ជាប់ជាមួយនូវសៀវភៅបន្ទុក កិច្ចសន្យា ឬ ឯកសារដែលបញ្ជាក់អំពីការិយបរិច្ឆេទត្រូវបង់ចំណូល ។
- តារាងចាត់ស្មានចំណាយ តារាងចំណាយនេះ ត្រូវរាយលំអិតតាមមាតិកាថវិកានិងគ្រោងតាមខែនីមួយៗ មិនត្រូវធ្វើគំរោងជាតួលេខរួមមួយត្រីមាសឡើយ ។ ចំពោះចំណាយជាគុណប្រយោជន៍របស់ ខេត្ត ក្រុង (ចំណាយដោយឡែករបស់ផ្នែក ជំពូក ១១ ប្រការ ០១ កថាខ័ណ្ឌ ១៤) ត្រូវភ្ជាប់មកជាមួយនូវគំរោងចំណាយលំអិតតាមការដ្ឋាននីមួយៗ ដូចជា បំភ្លឺសាធារណៈ និងផ្គត់ផ្គង់ទឹក អនាម័យសុខាភិបាល និងសង្គ្រោះសុខការសង្គ្រោះ

ដល់ជនក្រីក្រការរៀបចំថែទាំផ្លូវ ប្រព័ន្ធបញ្ចូលបញ្ចេញទឹក សូនច្បារប្រាំងទន្លេ.....ដែលបានអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ ត្រូវភ្ជាប់ជាមួយនូវសៀវភៅបន្ទុក កិច្ចសន្យា និងឯកសារដែលបញ្ជាក់អំពីពេលវេលាត្រូវទូទាត់ ។

៣.២ ចំណូលឧបត្ថម្ភពីថវិការដ្ឋសំរាប់វិនិយោគសាធារណៈ

ចំណូលនេះ គ្រាន់តែជាការផ្ទេរឥណទានថវិការដ្ឋសំរាប់អនុវត្តនូវកម្មវិធីចំណាយវិនិយោគសាធារណទៅក្នុងថវិកា ខេត្ត ក្រុង ដូច្នេះក្នុងករណីមានការឧបត្ថម្ភខេត្ត ក្រុង ត្រូវធ្វើសំណើត្រង់មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែម្តង ការស្នើនេះ បែកចេញជាពីរយ៉ាង ៖

ទី១. ឧបត្ថម្ភសំរាប់ចូលនិធិបរិភាគ(ជំពូក ៣១ ប្រការ ០២) ផ្អែកលើតួលេខដែលបានគ្រោងក្នុងសៀវភៅថវិកាខេត្ត ក្រុង ឬប្រកាសបន្ថែមឥណទាន ត្រូវធ្វើសំណើដោយភ្ជាប់មកជាមួយនូវគំរោងកម្មវិធីវិនិយោគសាធារណៈនៃ ហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលត្រូវអនុវត្តនៅខេត្ត ក្រុងរបស់ខ្លួន ។

ទី២. ឧបត្ថម្ភវិនិយោគដោយថវិការដ្ឋ (ជំពូក ៣១ ប្រការ ០៤) ផ្អែកលើតួលេខដែលបានគ្រោងក្នុងសៀវភៅថវិកាខេត្ត ក្រុង ឬប្រកាសបន្ថែមឥណទាន ត្រូវធ្វើសំណើដោយភ្ជាប់មកជាមួយនូវឯកសារដែលបានធ្វើលទ្ធកម្មសាធារណៈរួចតាមការដ្ឋានទីមួយៗ ។

ខ. អំពីចំណាយ

១. **ចំណាយចរន្ត** : ចំណាយចរន្តត្រូវអនុវត្តអោយបានម៉ឺងម៉ាត់ ទៅតាមគោលការណ៍និងនីតិវិធីដូចគ្នា នៃចំណាយថវិការដ្ឋដែរពោលគឺ ៖

- អំពីចំណាយបៀវត្សត្រូវអនុវត្តតាមរយៈភ្នាក់ងារបើកផ្តល់ អោយចំពោះបៀវត្សមូលដ្ឋាន និងប្រាក់កំរៃបុគ្គលិកអណ្តែត ភ្នាក់ងារជាប់កិច្ចសន្យា ត្រូវអនុវត្តតាមសេចក្តីសំរេចទទួលស្គាល់របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

- អំពីចំណាយតូចតាច និងចំណាយចាំបាច់បន្ទាន់ គឺត្រូវអនុវត្តតាមរយៈរដ្ឋទេយ្យបុរេប្រទានដែលកំណត់ឡើងដោយដីការបស់ខេត្ត ក្រុង ។ ពេលដកប្រាក់ពីរតនាគារ រដ្ឋទេយ្យករត្រូវមានប័ណ្ណដកប្រាក់ និងលិខិតឧទ្ទេសនាមរបស់អង្គភាព (ពុំចាំបាច់ធ្វើលិខិតស្នើសុំថ្លែងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទេ) ។

- អំពីចំណាយចរន្តផ្សេងៗទៀត គឺត្រូវអនុវត្តទៅតាមនីតិវិធីទូទាត់ត្រង់ជូនអ្នកផ្គត់ផ្គង់ ក្រោយពេលដែលទំនិញ ឬសេវាំនានា ត្រូវបានអនុវត្តរួចហើយ ។

- ដោយឡែកចំពោះជំពូក ៤១ "ចំណាយមិនបានគ្រោងទុក" ខេត្ត ក្រុងមិនត្រូវអនុវត្តចំណាយជំពូកនេះ ដោយផ្ទាល់ទេ ។ នៅពេលមានតំរូវការចំណាយ ខេត្ត ក្រុងត្រូវធ្វើសំណើសុំការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីបង្វែរឥណទានពីជំពូកនេះ ទៅជាប្រយោជន៍ដល់ជំពូកចំណាយដទៃទៀត ទៅតាមតំរូវការចំណាយជាក់ស្តែងនីមួយៗ ជាពិសេសសំរាប់បំពេញនូវការអភិវឌ្ឍន៍ខេត្ត ក្រុង ។

២. **ចំណាយជាមូលធន** : ចំពោះការចំណាយជាមូលធនគឺបែកចេញជាពីរ ៖

ទី១. ចំណាយសំរាប់ចូលនិធិបរិភាគ : ក្នុងពេលអនុវត្ត ខេត្ត ក្រុងត្រូវធ្វើអាណត្តិដោយគ្រាន់តែភ្ជាប់តាមនូវគំរោងកម្មវិធីវិនិយោគសាធារណៈនៃហិរញ្ញប្បទានពីក្រៅប្រទេសតែប៉ុណ្ណោះ ។ រតនាគារខេត្ត ក្រុង ត្រូវបើកផ្តល់ឬផ្ទេរឥណទាននេះទៅក្នុងគណនីម្ចាស់ជំនួយនៅរតនាគារខេត្ត ក្រុង ឬធនាគារ (បើមាន) ។

ទី២. ចំណាយវិនិយោគ : ចំណាយវិនិយោគ ទោះជាហិរញ្ញប្បទានដោយថវិកាខេត្ត ក្រុង ឬហិរញ្ញប្បទានដោយថវិការដ្ឋឧបត្ថម្ភក៏ដោយ គឺត្រូវតែបំពេញបែបបទ និងអនុវត្តអោយបានត្រឹមត្រូវទៅតាមនីតិវិធីលទ្ធកម្មសាធារណៈជាធរមាន ។

៣. ចំណាយបន្ថែមលើសពីគំរោងចំណាយថវិកាខេត្ត ក្រុងប្រចាំឆ្នាំ : យោងប្រការ ១២ នៃប្រកាសលេខ ២០៣ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីបទបញ្ញាថវិការបស់ខេត្ត ក្រុង បានចែងថា ឲ្យនៅក្នុងឆ្នាំថវិកា ប្រសិនបើចំណូលជាក់ស្តែងនៃថវិការបស់ខេត្ត ក្រុង បានកើនលើសពីគំរោងចំណូលប្រចាំឆ្នាំដែលបានគ្រោងទុកនោះ ឥណទានចំណាយថវិកាអាចត្រូវបង្កើនឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅតាមកំរិតចំណូលលើសដែលរតនាគារខេត្ត ក្រុងបានបញ្ជិការួចហើយ ។

ដូច្នេះ នៅត្រីមាសទី ៤ ខេត្ត ក្រុងត្រូវធ្វើការប៉ាន់ស្មានការអនុវត្តចំណូលប្រចាំឆ្នាំរបស់ខ្លួន ដោយមានមូលដ្ឋានជាក់លាក់ដែលអាចប្រមូលចំណូលបានយ៉ាងពិតប្រាកដ រួចប្រៀបធៀបជាមួយគំរោងចំណូលប្រចាំឆ្នាំ ។ ប្រសិនបើមានចំណូល លើសពីគំរោងចំណូលប្រចាំឆ្នាំ ខេត្ត ក្រុងអាចស្នើសុំបន្ថែមលើគំរោងចំណាយប្រចាំឆ្នាំ សំរាប់ចំណាយជាគុណប្រយោជន៍របស់ខេត្ត ក្រុង ដែលជាចំណាយសំរាប់វិនិយោគអភិវឌ្ឍន៍ខេត្ត ក្រុង ហើយខេត្ត ក្រុងត្រូវធ្វើសំណើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈក្រសួងមហាផ្ទៃ ដោយភ្ជាប់មកជាមួយនូវគំរោងចំណាយលំអិតតាមការដ្ឋាននីមួយៗផង ។

គ. ការធ្វើវិសហមជ្ឈការ លទ្ធកម្មសាធារណៈ

ក្នុងស្មារតីយកចិត្តទុកដាក់អនុវត្តកម្មវិធីកំណែទំរង់ហិរញ្ញវត្ថុសាធារណៈ និងដើម្បីលើកកំពស់ការទទួលខុស ត្រូវរបស់ឯកឧត្តមអភិបាលខេត្ត ក្រុង ក្នុងការអនុវត្តន៍ថវិការបស់ខ្លួនអោយបានទាន់ពេលវេលាក្នុងឆ្នាំ ២០០៥ នេះ ជាជំហានសាកល្បង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងចេញសេចក្តីប្រកាសស្តីពីការធ្វើវិសហមជ្ឈការកិច្ចលទ្ធកម្មសាធារណៈ ជំហានដំបូងជូនក្រសួងស្ថាប័នខេត្ត ក្រុងនិងសហគ្រាសសាធារណៈ ដូច្នេះ អភិបាលខេត្ត ក្រុងត្រូវយកចិត្តទុកដាក់អនុវត្តកិច្ចលទ្ធកម្មអោយបានត្រឹមត្រូវតាមសេចក្តីប្រកាសនេះ ។

ឃ. ការបង្វែរឥណទានផ្ទៃក្នុងជំពូក

យោងប្រការ ១៣ វាក្យខ័ណ្ឌទី ២ នៃប្រកាសលេខ ២០៣ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីបទបញ្ញាថវិការបស់ខេត្ត ក្រុង បានចែងថាឲ្យការបង្វែរពីប្រការមួយទៅប្រការមួយ ពីកថាខ័ណ្ឌមួយទៅកថាខ័ណ្ឌមួយ និងពីវាក្យខ័ណ្ឌមួយទៅវាក្យខ័ណ្ឌមួយ ដែលនៅក្នុងជំពូកតែមួយត្រូវធ្វើឡើងដោយដីការបស់អភិបាលខេត្ត ក្រុង បន្ទាប់ពីមានការឯកភាពរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ.....។ ប៉ុន្តែខេត្ត ក្រុងមិនត្រូវបង្វែរឥណទានពីជំពូក ១១ ប្រការ ០១ កថាខ័ណ្ឌ ១៤ (ចំណាយដោយខ្សែការរបស់ផ្នែក) ទៅចំណាយនៅកថាខ័ណ្ឌផ្សេងៗទៀតនៃជំពូក ១១ ដែលជាហេតុនាំអោយចំណាយសំរាប់ដំណើរការរដ្ឋបាលមានការកើនឡើង ហើយចំណាយសំរាប់ជាគុណប្រយោជន៍ ខេត្ត ក្រុង មានការថយចុះនោះទេ ។ ប្រសិនបើមានករណីចាំបាច់ខេត្ត ក្រុង ត្រូវធ្វើសំណើសុំការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងការអនុវត្តន៍ចំណាយជាគុណប្រយោជន៍ខេត្ត ក្រុង ត្រូវអនុវត្តអោយបានត្រឹមត្រូវទៅតាមនីតិវិធីហិរញ្ញវត្ថុ និងទៅតាមគំរោងនៃការដ្ឋាននីមួយៗ ដែលខេត្ត ក្រុងបានលើកក្នុងផែនការអភិវឌ្ឍន៍ និងមានការពិភាក្សាឯកភាពពីក្រសួងមហាផ្ទៃរួចហើយ ។ នៅពេលអនុវត្តប្រសិនបើខេត្ត ក្រុងមានការចាំបាច់ត្រូវផ្លាស់ប្តូរគំរោងចំណាយ

នៃការដ្ឋានណាមួយនោះ ខេត្ត ក្រុងត្រូវស្នើសុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាមុនទើបអាចចាប់ផ្តើមអនុវត្តគំរោងចំណាយសំរាប់ការដ្ឋានថ្មីបាន ។

ខាងលើនេះ គឺជាការណែនាំបន្ថែមក្នុងកិច្ចប្រតិបត្តិការថវិកាខេត្ត ក្រុងអោយចំទិសដៅនិងមានប្រសិទ្ធភាព សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ដោយឡែកប្រកាសណែនាំស្តីពីកិច្ចប្រតិបត្តិការអនុវត្តថវិកាខេត្ត ក្រុង លេខ ២០៥ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលមិនផ្ទុយនឹងប្រកាសនេះ នៅតែរក្សាសុពលភាពដដែល ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៥

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចំលងជូនៈ

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ

(ដើម្បីជូនជ្រាប)

- គ្រប់សាលាខេត្ត ក្រុង
- គ្រប់មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត ក្រុង
- គ្រប់រតនាគារខេត្ត ក្រុង
- គ្រប់សាខាពន្ធដារខេត្ត ក្រុង

(ដើម្បីអនុវត្ត)

- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

លេខ : ០០២/ប.ក ២០០៥

រាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៥

ប្រកាស

ស្តីពីការចេញបណ្ណ និងផ្លាកលេខសំគាល់យានជំនិះ ក្នុងកងយោធពលខេមរភូមិន្ទ

*****

សមាជិកមន្ត្រីក្រសួងការពារជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទី ភារៈកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីការចេញផ្លាកលេខសំគាល់យានជំនិះ
- បានឃើញសេចក្តីសំរេចលេខ ០៤២/០៤ ស.ស.រ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការចេញប័ណ្ណអាវុធខ្លី ផ្លាកលេខសំគាល់សំភារៈសឹក ប័ណ្ណបើកបរ ប័ណ្ណសំគាល់ និងផ្លាកលេខយានយន្តគ្រប់ប្រភេទរបស់ក្រសួងការពារជាតិ ។

- ដើម្បីធានាដល់ការគ្រប់គ្រងយានជំនិះគ្រប់ប្រភេទក្នុងកងយោធពលខេមរភូមិន្ទ អោយមានសណ្តាប់ធ្នាប់របៀបរៀបរយនិងការប្រើប្រាស់ផ្លាកលេខចរាចរបានត្រឹមត្រូវតាមច្បាប់កំណត់ ។

សម្រេច

ប្រការ ១ : កំណត់ទូទៅ

១.១- ត្រូវបានផ្លាស់ប្តូរប័ណ្ណសំគាល់យានយន្ត និងផ្លាកលេខចរាចររបស់កងយោធពលខេមរភូមិន្ទ ដែលបានចេញអោយប្រើប្រាស់កន្លងមក ហើយប្រើប្រាស់ប័ណ្ណសំគាល់យានយន្ត និងផ្លាកលេខចរាចរថ្មី ។

១.២- យានយន្តគ្រប់ប្រភេទ ដែលត្រូវបានផ្តល់ប័ណ្ណសំគាល់ និងផ្លាកលេខចរាចរ គឺយានយន្ត ដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ ហើយត្រូវបានចុះបញ្ជីសារពើភ័ណ្ឌ ដូចជាយានយន្តដែលរដ្ឋបំពាក់ អំណោយពីគ្រប់មជ្ឈដ្ឋាន ជំនួយបរទេស និងរបស់ក្រុមបេសកកម្មយោធាបរទេស ដែលប្រចាំរយៈពេលយូរ ។

១.៣- យានយន្តដែលត្រូវបានផ្តល់ប័ណ្ណសំគាល់ និងប្រើប្រាស់ផ្លាកលេខចរាចរ របស់កងយោធពលខេមរភូមិន្ទ ត្រូវបានកំណត់ប្រភេទ ដូចខាងក្រោម :

- ប្រភេទទី ១ : ទោចក្រយានយន្ត ត្រីចក្រយានយន្ត
- ប្រភេទទី ២ : រថយន្តតូច
- ប្រភេទទី ៣ : រថយន្តដឹកជញ្ជូនធុនស្រាល និងធុនធ្ងន់
- ប្រភេទទី ៤ : យានយន្តឧបករណ៍
- ប្រភេទទី ៥ : ក្បាលរថយន្តសណ្តោង . រ៉ឺម៉ក . សឺមីរ៉ឺម៉ក
- ប្រភេទទី ៦ : គ្រឿងយន្តវិស្វកម្ម
- ប្រភេទទី ៧ : គ្រឿងយន្តកសិកម្ម

ប្រការ ២ : រូបភាព ផ្លាកលេខចរាចរ និងប័ណ្ណសំគាល់យានយន្ត

២.១- ផ្លាកលេខចរាចរ មានសរសេរជាអក្សរខ្មែរ អក្សរឡាតាំង លេខកូដសំគាល់ស្ថាប័នកងឯកភាព និងលេខកូដសំគាល់យានយន្តពណ៌ស ផ្ទៃពណ៌ខៀវខាងលើ ពណ៌ក្រហមខាងក្រោម ។

២.២- ប័ណ្ណសំគាល់យានយន្ត មានសរសេរលេខចរាចរម្ខាង និងម្ខាងទៀតមានសរសេរភិនភាគយានយន្ត ។

២.៣- ចំពោះលេខកូដសំគាល់ស្ថាប័នកងឯកភាព ប្រភេទយានជំនិះ និងលេខកូដចរាចរ អក្សរមានសរសេរនៅលើផ្លាកលេខសំគាល់យានជំនិះ ។

២.៤- យានយន្តរបស់កងយោធពលខេមរភូមិន្ទ ជាមធ្យោបាយដឹកជញ្ជូន អូសសណ្តោងសំភារៈយោធា ឬដឹកជញ្ជូនកងទ័ព ត្រូវមានសញ្ញាសំគាល់អង្គភាព លាបពណ៌គ្រែអ៊ី និងពណ៌ពិសេសផ្សេងៗទៀត ត្រូវបានកំណត់ដោយក្រសួងការពារជាតិ ។

<u>ប្រការ ៣</u> : លក្ខខណ្ឌប្រើប្រាស់

៣.១- អនុញ្ញាតអោយប្រើប្រាស់ប័ណ្ណសំគាល់ ផ្លាកលេខចរាចរ ចំពោះតែយានយន្តដូចដែលបានកំណត់ក្នុង ប្រការ.១ ។

៣.២- គ្រប់ស្ថាប័នកងឯកភាពត្រូវបំពេញបែបបទ ដើម្បីស្នើសុំប័ណ្ណសំគាល់យានយន្ត និងផ្លាកលេខចរាចរថ្មី តាមឋានានុក្រម និងតាមការណែនាំរបស់សមត្ថកិច្ចជំនាញទទួលបន្ទុក ដោយមានភ្ជាប់មកជាមួយនូវបញ្ជីរៀបរាប់លំអិតអំពីបរិមាណ គុណភាព និងប្រភពបំពាក់អោយបានច្បាស់លាស់ ។

៣.៣- គ្រប់មធ្យោបាយយានយន្តត្រូវពាក់ផ្លាកលេខអោយបានត្រឹមត្រូវនៅផ្នែកខាងមុខ និងផ្នែកខាងក្រោយយានយន្ត ។ ចំពោះយានយន្តដែលមានលក្ខណៈពិសេស ត្រូវពាក់ផ្លាកលេខនៅទីកន្លែងមួយជាក់លាក់ ដែលងាយស្រួលក្នុងការពិនិត្យ ។ មិនត្រូវធ្វើការឆ្នៃប្រឌិត តុបតែងបន្ថែមលើផ្លាកលេខធ្វើអោយខុសពីលក្ខណៈដើម ដែលច្បាប់បានកំណត់ ។

៣.៤- ការចេញប័ណ្ណ និងផ្លាកលេខសំគាល់យានយន្តអាចធ្វើទៅបាន លុះត្រាតែយានយន្តទាំងនោះបានបំពេញកាតព្វកិច្ចបង់ពន្ធនាំចូលតាមច្បាប់កំណត់របស់រដ្ឋ និងមានលក្ខណៈដូចចែងក្នុងប្រការ ១ ។

៣.៥- ចំពោះរថយន្តដែលខូចខាតមិនអាចប្រើប្រាស់បាន ដែលស្ថិតនៅក្នុងបញ្ជីគ្រប់គ្រង និងពុំទាន់មានសេចក្តីសំរេចផ្តាក់លើកាត់ចេញពីបញ្ជីគ្រប់គ្រង គឺត្រូវបានរក្សាទុកក្នុងបញ្ជី និងបញ្ចូលក្នុងស្ថិតិ ដែលត្រូវស្នើសុំប័ណ្ណសំគាល់យានយន្ត និងផ្លាកលេខចរាចរថ្មី រហូតដល់ពេលមានសេចក្តីសំរេចពីក្រសួងការពារជាតិ ។

- ចំពោះយានយន្តដែលធ្វើការផ្លាស់ប្តូរម៉ាស៊ីន ឬតួយានយន្ត ឬធ្វើអោយបាត់ប័ណ្ណសំគាល់ផ្លាកលេខចរាចរថ្មីនេះ ត្រូវធ្វើបែបបទដើម្បីសុំកែសំរួល ប័ណ្ណសំគាល់ ផ្លាកលេខចរាចរថ្មីទៀត សំរាប់ប្រើប្រាស់អោយត្រឹមត្រូវតាមស្ថានភាពជាក់ស្តែងរបស់យានយន្ត ។

<u>ប្រការ ៤</u> : សមត្ថកិច្ចគ្រប់គ្រង ការចេញប័ណ្ណសំគាល់ និងកាលបរិច្ឆេទ

៤.១- គ្រប់ស្ថាប័នកងឯកភាព ត្រូវបំពេញបែបបទស្នើសុំប័ណ្ណសំគាល់យានយន្ត និងផ្លាកលេខចរាចរ តាមសមត្ថកិច្ចជំនាញ និងបានការទទួលស្គាល់របស់មេបញ្ជាការស្ថាប័នកងឯកភាព ឆ្លងតាមឋានានុក្រមមកក្រសួងការពារជាតិ ដើម្បីពិនិត្យផ្តល់ ជូនសំរាប់ប្រើប្រាស់ ។ គំរោងស្នើសុំត្រូវភ្ជាប់មកជាមួយនូវបញ្ជីស្ថិតិ ដូចមានចែងក្នុងប្រការ ៣ ។

៤.២- អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស មានភារៈកិច្ចពិនិត្យលើគំរោងស្នើសុំរបស់បណ្តាស្ថាប័នកងឯកភាព និងធ្វើការចេញប័ណ្ណសំគាល់យានយន្ត និងផ្លាកលេខចរាចរ អោយដល់ស្ថាប័នកងឯកភាពសំរាប់យកទៅប្រើប្រាស់ ។

៤.៣- គ្រប់ស្ថាប័នកងឯកភាពក្នុងកងយោធពលខេមរភូមិន្ទ ត្រូវធ្វើបែបបទ ដើម្បីស្នើសុំប័ណ្ណសំគាល់យានយន្ត និងផ្លាកលេខចរាចរថ្មី ដើម្បីបំពាក់អោយយានយន្តរបស់ស្ថាប័នកងឯកភាព ដូចក្នុងប្រការ ១ អោយបានចប់សព្វគ្រប់នូវដំណាច់ខែធ្នូ ឆ្នាំ ២០០៥ យ៉ាងយូរបំផុត ។

៤.៤ - ផ្លាកលេខចរាចរចាស់ ដែលអគ្គបញ្ជាការបានចេញ ត្រូវបញ្ចប់ត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០៤ ។

<u>**ប្រការ ៥**</u> : ជនណាប្រើប្រាស់ផ្លាកលេខ ខ.ម ក្លែងក្លាយ និងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ការត្រួតពិនិត្យយានយន្តរបស់កងយោធពលខេមរភូមិន្ទ ជាភារៈកិច្ចតែមួយគត់របស់កងរាជអាវុធហត្ថ ។

<u>**ប្រការ ៦**</u> : ខ្ទឹមសារនៃសេចក្តីណែនាំ សេចក្តីកំណត់ទាំងឡាយ ដែលផ្ទុយនិងខ្ទឹមសារនៃសេចក្តីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

<u>**ប្រការ ៧**</u> : អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គលេខាធិការ ក្រសួងការពារជាតិ អគ្គនាយក អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស មេបញ្ជាការកងទ័ពជើងគោក មេបញ្ជាការកងទ័ពជើងទឹក មេបញ្ជាការកងទ័ពជើងអាកាស មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គនាយក នាយក ប្រធាន មេបញ្ជាការស្ថាប័នកងឯកភាពចំណុះក្រសួងការពារជាតិនិងអគ្គបញ្ជាការដ្ឋានត្រូវមានវិធានការផ្សព្វផ្សាយ និងអនុវត្តសេចក្តីប្រកាសនេះ អោយបានម៉ឺងម៉ាត់និងមានប្រសិទ្ធិភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយឧ.ផ្កាយមាស៤ **ទៀ-បាញ់**   នាយឧ.ផ្កាយមាស៤.ញឹក-ប៊ុនឆៃ

<u>ផ្ញើជូន</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសាធារណការនិងដឹកជញ្ជូន
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

  " ដើម្បីជូនជ្រាប "
- ដូចប្រការ ៧

  " ដើម្បីអនុវត្ត "
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
លេខ : ០០១/ស.ន.ច
២០០៥

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែមករា ឆ្នាំ២០០៥

សារាចរណែនាំ
ស្តីពីការចេញប័ណ្ណ និងផ្លាកលេខសំគាល់យានជំនិះគ្រប់ប្រភេទ ក្នុងកងយោធពលខេមរភូមិន្ទ

យោងអនុក្រឹត្យលេខ ៧៧ អន.ក្របក ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីការចេញផ្លាកលេខសំគាល់យានជំនិះ និងអនុវត្តតាមសេចក្តីសំរេចលេខ ០៤២/០៤ ស.ស.រ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការចេញប័ណ្ណអាវុធខ្លី ផ្លាកលេខសំគាល់សំភារៈសឹក ប័ណ្ណបើកបរ ប័ណ្ណសំគាល់ និងផ្លាកលេខយានយន្តគ្រប់ប្រភេទរបស់ក្រសួងការពារជាតិ ដើម្បីបង្កការងាយស្រួលក្នុងការគ្រប់គ្រង បែងចែកច្បាស់លាស់នូវប្រភេទយានយន្ត យានជំនិះ លេខកូដសំរាប់សំគាល់ស្ថាប័នកងឯកភាព និងធានាបាននូវសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ព្រមទាំងការប្រើប្រាស់ផ្លាកលេខចរាចរបានត្រឹមត្រូវ ស្របតាមតម្រូវការចាំបាច់របស់កងយោធពលខេមរភូមិន្ទ ក្រសួងការពារជាតិសូមធ្វើការណែនាំដូចខាងក្រោម :

១- ប័ណ្ណ និងផ្លាកលេខសំគាល់យានជំនិះគ្រប់ប្រភេទ របស់កងយោធពលខេមរភូមិន្ទ សំរាប់ប្រើប្រាស់បំរើការងារការពារជាតិ និងនៅសមរភូមិ យានជំនិះដែលបានមកដោយប្រើប្រាស់ថវិការដ្ឋ ត្រូវពាក់លេខរដ្ឋ យានជំនិះដែលបានមកដោយថវិកាឯកជន ត្រូវពាក់ផ្លាកលេខឯកជន យានជំនិះមួយគ្រឿងមានលេខសំគាល់ (លេខចុះបញ្ជី) តែមួយគត់ លេខសំគាល់នេះត្រូវប្រើប្រាស់រហូតដល់យានជំនិះខូច មិនអាចជួសជុលបាន (គុណភាពគីត ៥) លេខសំគាល់អាចប្តូរបានលុះត្រាតែយានជំនិះត្រូវបានផ្លាស់ប្តូរស្ថាប័នកងឯកភាព ។

២- យានជំនិះរបស់កងយោធពលខេមរភូមិន្ទ ត្រូវបានបែងចែកជា ៧ ប្រភេទគឺ :

- ប្រភេទទី ១ : ទោចក្រយានយន្ត ត្រីចក្រយានយន្ត
- ប្រភេទទី ២ : រថយន្តតូច
- ប្រភេទទី ៣ : រថយន្តដឹកជញ្ជូនធុនស្រាល និងធ្ងន់
- ប្រភេទទី ៤ : យានយន្តបច្ចេកទេស
- ប្រភេទទី ៥ : ក្បាលរថយន្តសណ្តោង . រ៉ឺម៉ក .សឺមីរ៉ឺម៉ក

- ប្រភេទទី ៦ : គ្រឿងយន្តវិស្វកម្ម
- ប្រភេទទី ៧ : គ្រឿងយន្តកសិកម្ម

៣- លេខកូដសំគាល់ស្ថាប័នកងឯកភាពមាន ១០ ប្រភេទ :

- ក្រសួងការពារជាតិ លេខកូដសំគាល់លេខ ១
- អគ្គបញ្ជាការដ្ឋាន លេខកូដសំគាល់លេខ ២
- យោធភូមិភាគ ១ លេខកូដសំគាល់លេខ ៣
- យោធភូមិភាគ ២ លេខកូដសំគាល់លេខ ៤
- យោធភូមិភាគ ៣ លេខកូដសំគាល់លេខ ៥
- យោធភូមិភាគ ៤ លេខកូដសំគាល់លេខ ៦
- យោធភូមិភាគ ៥ លេខកូដសំគាល់លេខ ៧
- យោធភូមិភាគពិសេស លេខកូដសំគាល់លេខ ៨
- កងរាជអាវុធហត្ថលើផ្ទៃប្រទេស លេខកូដសំគាល់លេខ ៩
- ក្រុមបេសកកម្មយោធាបរទេស លេខកូដសំគាល់លេខ ១០

៤- លក្ខណៈសំគាល់ប័ណ្ណ និងផ្លាកលេខសំគាល់យានជំនិះគ្រប់ប្រភេទ :

* ប័ណ្ណសំគាល់ :

- ផ្ទៃ និង ពណ៌ : មានផ្ទៃពណ៌ខៀវខាងលើ ក្រហមខាងក្រោមចែកពាក់កណ្តាលស្មើ ។ អក្សរ និង លេខពណ៌ស ។
- អក្សរ និងលេខ : មានអក្សរ ជាភាសាខ្មែរ និងលេខឡាតាំង ។
- រូបសណ្ឋាន : មានរាងជាចតុកោណកែង ។

(ឧបសម្ព័ន្ធទី ១)

* ផ្លាកលេខសំគាល់យានជំនិះ :

បន្ទះដែកសំរាប់ចាប់ភ្ជាប់ទៅនឹងយានយន្តមុខ-ក្រោយ

- ផ្ទៃ និងពណ៌ : មានផ្ទៃពណ៌ខៀវខាងលើ ក្រហមខាងក្រោម ចែកពាក់កណ្តាលស្មើ ។ អក្សរ និង លេខពណ៌ស ។
- អក្សរ និងលេខ : មានអក្សរជាភាសាខ្មែរ និងភាសាអង់គ្លេស ព្រមទាំងមានលេខកូដសំគាល់ ស្ថាប័នកងឯកភាពនៅខាងលើ និងសំគាល់ប្រភេទយានជំនិះនៅដើមលេខចាចរ ។
- រូបសណ្ឋាន : មានរាងជាចតុកោណកែង ។
- ទំហំ : ផ្លាកលេខខាងមុខ និងក្រោយមានទំហំខុសគ្នា ។

(ឧបសម្ព័ន្ធទី ២)

* ផ្លាកសញ្ញាសំគាល់កងឯកភាព :

ជា Sticker សំរាប់បិទនៅសងខាងទ្វារខាងមុខយានយន្ត

- ផ្ទៃ និងពណ៌ : មានផ្ទៃពណ៌ខៀវខាងលើ ក្រហមខាងក្រោម ចែកពាក់កណ្តាលស្មើរូបសញ្ញា និងអក្សរពណ៌ស ។

- រូបសញ្ញានិងអក្សរ : មានរូបសញ្ញាសំគាល់ស្ថាប័នកងឯកភាពនៅចំកណ្តាលនិងមានអក្សរជាភាសាខ្មែរសរសេរកោងនៅពីក្រោម ។

- រូបសណ្ឋាន : មានរាងជារង្វង់មូល ។

(ឧបសម្ព័ន្ធទី ៣)

៥- លក្ខខ័ណ្ឌប្រើប្រាស់ :

- យានជំនិះគ្រប់ប្រភេទ ដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ ហើយនឹងត្រូវចុះក្នុងបញ្ជីសារពើភ័ណ្ឌដូចជា យានជំនិះបានមកជាជំនួយ-រដ្ឋបំពាក់-អំណោយពីគ្រប់មជ្ឈដ្ឋាន រៀបចំតម្លើងកែច្នៃក្នុងប្រទេស ជួសជុលរៀបតម្លើង និងយានយន្តរបស់ក្រុមបេសកកម្មយោធាបរទេស ។

- គ្រប់យានជំនិះ ត្រូវពាក់ផ្លាកលេខចរាចរអោយបានត្រឹមត្រូវនៅផ្នែកខាងមុខ និងផ្នែកខាងក្រោយ ។ ចំពោះយានយន្តដែលមានលក្ខណៈពិសេស ត្រូវពាក់ផ្លាកលេខសំគាល់យានយន្ត នៅទីកន្លែងមួយជាក់លាក់ ដែលងាយស្រួលក្នុងការមើល និងពិនិត្យ ។ មិនត្រូវធ្វើការច្នៃប្រឌិត គូបតែងលើផ្លាកលេខសំគាល់យានជំនិះ ដែលនាំអោយខុសពីលំនាំដើម ដែលបានកំណត់ ។

- ការចេញប័ណ្ណ និងផ្លាកលេខសំគាល់យានជំនិះ អាចធ្វើទៅបានលុះត្រាតែយានជំនិះទាំងនោះ ត្រូវបាននាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ដោយស្របច្បាប់ជាធរមាន និងត្រូវបានបំពេញកាតព្វកិច្ចពន្ធដារនៃការនាំចូលនោះសព្វគ្រប់ហើយ ។

- ចំពោះយានជំនិះខូចខាតមិនអាចប្រើប្រាស់បាន (គុណភាពគីរ៉េ ៥) ត្រូវរក្សាទុកក្នុងបញ្ជីគ្រប់គ្រងរហូតដល់មានសេចក្តីសំរេចពីក្រសួងការពារជាតិ ទើបអាចកាត់ចេញបាន យានជំនិះខាងលើនេះមិនត្រូវបានផ្តល់ប័ណ្ណ និងផ្លាកលេខសំគាល់យានជំនិះអោយប្រើប្រាស់ឡើយ ។

- ចំពោះយានជំនិះដែលធ្វើការផ្លាស់ប្តូរម៉ាស៊ីន ឬ តួយានជំនិះ ឬធ្វើអោយបាត់ប័ណ្ណ ផ្លាកលេខបាត់ ត្រូវធ្វើសំណើស្នើសុំជាថ្មី ដើម្បីកែសំរួលប័ណ្ណសំគាល់យានជំនិះថ្មីទៀត សំរាប់ប្រើប្រាស់អោយបានត្រឹមត្រូវតាមស្ថានភាពជាក់ស្តែងរបស់យានជំនិះ ។

៦- សមត្ថកិច្ចគ្រប់គ្រង :

- គ្រប់ស្ថាប័នកងឯកភាពត្រូវបំពេញបែបបទស្នើសុំប័ណ្ណសំគាល់និងផ្លាកលេខសំគាល់យានជំនិះគ្រប់ប្រភេទពុំទាន់មានផ្លាកលេខតាមសមត្ថកិច្ចជំនាញនិងបានទទួលស្គាល់របស់មេបញ្ជាការទទួលបន្ទុកការងារជំនាញរបស់ស្ថាប័នកងឯកភាព ឆ្លងតាមឋានានុក្រម មកអគ្គនាយកដ្ឋានសំភារៈបច្ចេកទេស ក្រសួងការពារជាតិ ។

- អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស ក្រសួងការពារជាតិ មានភារៈកិច្ចគ្រប់គ្រង ពិនិត្យសំណើស្នើ និងផ្តល់ជូននូវប័ណ្ណ និងផ្លាកលេខសំគាល់យានជំនិះគ្រប់ប្រភេទរបស់កងយោធពលខេមរភូមិន្ទជាបន្ត ។

- អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស មានភារៈកិច្ចធ្វើសេចក្តីរាយការណ៍ជូនក្រសួងការពារជាតិ អំពីស្ថិតិយានជំនិះដែលប្រើប្រាស់ផ្លាកលេខសំគាល់របស់កងយោធពលខេមរភូមិន្ទ ។

ទទួលបានសារាចរណែនាំនេះ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គលេខាធិការក្រសួងការពារជាតិ អគ្គនាយក អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស មេបញ្ជាការកងទ័ពទាំង ៣ ប្រភេទ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គនាយក នាយក ប្រធានស្ថាប័នចំណុះក្រសួងការពារជាតិ និងអគ្គបញ្ជាការដ្ឋាន ត្រូវអនុវត្តតាមខ្លឹមសារខាងលើអោយបានសំរេចលទ្ធផលជាវិជ្ជមាន ។

ឧបនាយករដ្ឋមន្ត្រី ទៀ_បាញ់ ឧបនាយករដ្ឋមន្ត្រី ញឹក_ប៊ុនឆៃ

<u>ផ្ញើជូន</u> :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងសាធារណការនិងដឹកជញ្ជូន

  " ដើម្បីជូនជ្រាប "

- អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ
- អគ្គលេខាធិការក្រសួងការពារជាតិ
- អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស
- មេបញ្ជាការកងទ័ពទាំង បី ប្រភេទ
- មេបញ្ជាការកងរាជអាវុធហត្ថ
- គ្រប់ស្ថាប័នកងឯកភាពចំណុះក្រសួង និងអគ្គបញ្ជាការដ្ឋាន

  " ដើម្បីអនុវត្ត "

- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ 009 ពណ.ឧតក

ភ្នំពេញថ្ងៃទី 06 ខែមករា ឆ្នាំ ២០០5

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ដុង ថាប អ៊ិនវេសមេន**

DONG THAP INVESTMENT Co.,Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 2200/04E ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៤

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន :

លោក	QUAN CHI	ប្រធានក្រុមប្រឹក្សាភិបាល
លោក	LE KHAI	អភិបាល
លោក	NGUYEN HOANG VU	អភិបាល
លោក	ចាន់ សុខណ្ណា	អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ៦១ ភូមិក្បាលទំនប់ សង្កាត់ បឹងទំពុន ខណ្ឌ មានជ័យ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម :

-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការដឹកជញ្ជូនទំនិញ ទំនិញគ្រប់ប្រភេទ-ការផ្គត់ផ្គង់សំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម

ស្តីទីប្រចាំការ

គឹម_ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ធនាគារជាតិកម្ពុជា
- ក្រសួងពត៌មាន
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- សាលា ក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០០៤ ពណ.នគគ

ភ្នំពេញថ្ងៃទី ០៦ ខែមករា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ភី អេស អិន អិចប្រេស ឃ្លារេនស៍**

PSN EXPRESS CLEARANCE Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 7339/04P ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៤

មានទម្រង់ជា : ក្រុមហ៊ុនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោកស្រី **ភាវ៉ង គឹមឡេង** ប្រធានក្រុមប្រឹក្សាភិបាល

លោកស្រី **ផុន ដានី** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ៥៥៩ Eo ផ្លូវកម្ពុជាក្រោម សង្កាត់ផ្សារដេប៉ូទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងទុកផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ចូន និងចែកចាយទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពានថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម_ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០០៥ ពណ.នគក

ភ្នំពេញថ្ងៃទី ០៤ ខែមករា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ស៊ី-អិល-អេហ្វ-ស៊ី ត្រេឌីង**

C-L-F-C TRADING Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 7329/04P ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៤

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **ទុំ សារិទ្ធិ**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ២៣២E2 ផ្លូវលេខ ៤៥ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងទុកផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងថែរក្សាទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម_ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០៦៨ ពណ.នគក

ភ្នំពេញថ្ងៃទី ០៤ ខែមករា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ស៊ី-អេ-ស៊ី-អេច អ៊ិមផត អិចផត**

C-A-C-H IMPORT EXPORT Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 7328/04P ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៤

មានទម្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **ម៉ុង ពិសិដ្ឋ**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៣ ផ្លូវលេខ ២០៨ សង្កាត់ក្រាំងធ្នង់ ខណ្ឌដង្កោ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម,

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ជ.រដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

គីម_ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០០៧ ពណ.នគក

ភ្នំពេញ ថ្ងៃទី០៤ ខែមករា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **យាយម្លូ អ៊ីមផត អិចផត**
YIEY MLOU IMPORT EXPORT Co.,Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 7315/04P ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៤

មានទម្រង់ជា : ក្រុមហ៊ុនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : កញ្ញា **ឡាវ ចៀខ** ប្រធានក្រុមប្រឹក្សាភិបាល
លោក **ផាន សេខ** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៤0E1 ផ្លូវលេខ ៥៥ ក្រុម៣២ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកព័ត៌មានសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពានថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ហ្ម៊ុយជានាធិការ

ការ

ចាម_ប្រាសិទ្ធ

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ [illegible] ពណ.ឧតក

ភ្នំពេញថ្ងៃទី ០៤ ខែមករា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អេស.ប៊ី.ប៊ី.ភី គ្រុប**
S.B.b.p GROUP Co.,Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 7301/04P ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៤

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោកស្រី **សួន នីនី** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ០២ ផ្លូវ ២០០ សង្កាត់ បឹងរាំង ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម :
-សេវារកការងារជូនអតិថិជនក្នុងនិងក្រៅប្រទេស
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ
-នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ
-ការជួសជុលសំភារៈទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
